# សុន្ទរកថា

## ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## និងជាប្រធាន គ.ជ.អ.ប ក្នុងពិធីបិទវេទិកាគណនេយ្យភាពសង្គម
## ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤

- **ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ តំណាងក្រសួង ស្ថាប័ននានា**
- **លោក** Enrique Aldaz-Carroll **ប្រធានស្តីទីពីធនាគារពិភពលោកប្រចាំកម្ពុជា**
- **លោកស្រី អស់លោកតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាទីមេត្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួមនិងថ្លែងសុន្ទរកថា ក្នុងឱកាសបិទ **អង្គវេទិកាស្តីពីគណនេយ្យភាពសង្គម** ដែលសហការរៀបចំឡើងដោយភ្នាក់ងារអនុវត្តគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន ទាំងស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋ ក្រោមការឧបត្ថម្ភរបស់ធនាគារពិភពលោក ។ ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមរបស់ ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ អន្តរជាតិ លោកស្រី អស់លោក ក្នុងវេទិការយៈពេល ២ថ្ងៃ ដែលបានបង្កើននូវភាពយោគយល់គ្នាកាន់ តែប្រសើរឡើង និងឈានទៅការពង្រឹងភាពជាដៃគូកាន់តែរឹងមាំរវាងស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋ សំដៅបន្តរួមចំណែកកែលម្អអភិបាលកិច្ច ការផ្តល់សេវា និងការអភិវឌ្ឍន៍មូលដ្ឋាន រួមចំណែក លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានទូទាំងប្រទេស ឱ្យកាន់តែប្រសើរឡើងក្នុងគោលដៅ ។ ការកសាងភាពជាដៃគូនេះក៏ជាទុនមួយដ៏សំខាន់សំរាប់រួមចំណែក ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលនឹងបន្តសំរាប់អណត្តិក្រោយៗទៀត។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

រយៈពេលជាង២០ឆ្នាំចុងក្រោយនេះ បន្ទាប់ពីមានការបោះឆ្នោត និងការប្រកាសដាក់អោយប្រើប្រាស់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម និងកំណែទម្រង់ដែលបានចាប់ផ្តើមពីឆ្នាំ ១៩៩៣ រហូតមកដល់បច្ចុប្បន្ន កំពុងត្រូវបាននឹងបន្តជំរុញអនុវត្តប្រកបដោយផ្លែផ្កា។ នីតិរដ្ឋសិទ្ធសេរីភាពរបស់ប្រជាជន សេរីភាពសារព័ត៌មាននិងការបញ្ចេញមតិ សកម្មភាពរបស់បណ្តា គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល សេវាសាធារណៈ សុវត្ថិភាពនៃសម្លេងប្រឆាំង និងការបោះឆ្នោតសុទ្ធតែត្រូវបានការពារពង្រឹង និងលើកកម្ពស់ឥតឈប់ឈរ។ បណ្តាស្ថាប័នទាំងឡាយ ដែលកើតចេញពីការបោះឆ្នោតនិងរដ្ឋបាលគ្រប់ថ្នាក់បានបំពេញនូវតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយ ប្រសិទ្ធភាព និងមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ប្រការទាំងនេះបានបង្ហាញច្បាស់ថាលទ្ធិប្រជាធិបតេយ្យ នៅកម្ពុជាបន្តមានការអភិវឌ្ឍឥតឈប់ឈរទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ចាប់តាំងពីឆ្នាំ ២០១២ កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិកាន់តែមានលក្ខណៈស៊ីជម្រៅ។ រចនាសម្ព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិតេយ្យនៅថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញ ស្របតាមគោលការណ៍ដែលបានចែងក្នុងច្បាប់រៀបចំអង្គការ ហើយកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងផែនការអនុវត្តរយៈពេល៤ឆ្នាំដំបូង នៃកម្មវិធីជាតិនេះក៏បាននិងកំពុងអនុវត្តយ៉ាងសកម្មផងដែរ។ ការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ក៏បានបង្ហាញនូវលទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់ ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ហើយកំណែទម្រង់ជាប្រវត្តិសាស្ត្រនេះ ពិតជាបានរួមចំណែកដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន។ ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ប្រជាជន ការពង្រឹងភាពជាអ្នកដឹកនៅមូលដ្ឋាន ទាំងបុរស ទាំងស្ត្រី ក៏បានធ្វើឱ្យមានការកែលម្អការផ្តល់សេវាសាធារណៈនៅមូលដ្ឋានផងដែរ។

ជាមួយគ្នានេះរាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ គឺដើម្បីបំរើប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើងហើយចំណុចនេះគឺជាគោលដៅយុទ្ធសាស្ត្រ និងជាត្រីវិស័យក្នុងការអនុវត្តការដ្ឋានកំណែទម្រង់ជាអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។នៅក្នុងការពង្រឹងអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលមានគោលដៅពង្រឹងអភិបាលកិច្ចនៅមូលដ្ឋាន និងការផ្តល់សេវាសាធារណៈបានផ្តល់ឱកាសថ្មីៗថែមទៀត សម្រាប់លើកកម្ពស់គោលការណ៍ប្រជាធិបតេយ្យបង្កើនកាលានុវត្តភាពនៃការអភិវឌ្ឍ កាត់បន្ថយភាពក្រីក្រ និងធានាស្ថិរភាព សមធម៌ និងការចូលរួមក្នុងកិច្ចការអភិវឌ្ឍ។

រាជរដ្ឋាភិបាលក៏កំពុងខិតខំអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវការប្រឆាំងអំពើពុករលួយ ជាពិសេសលុបបំបាត់ការយកកម្រៃខុសច្បាប់លើការផ្តល់សេវារដ្ឋបាលនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កំរិត ដោយអនុវត្តឱ្យបានហ្មត់ចត់នូវខ្លឹមសារអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៦៨អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ។

លើសពីនេះទៅទៀតរាជរដ្ឋាភិបាល ទទួលស្គាល់ថាកម្ពុជានៅមានផ្លូវដ៏វែង សំរាប់ធ្វើដំណើរ ហើយត្រូវពុះពារឆ្លងកាត់ឧបសគ្គរាប់មិនអស់ថែមទៀត ដើម្បីសម្រេចបាននូវវឌ្ឍនៈភាព និងវិបុលភាព។ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតែបន្តជាគោលដៅដ៏ចំបងបំផុតរបស់រាជរដ្ឋាភិបាល។ បញ្ហានៃភាពក្រីក្រនេះក៏ត្រូវទាមទារពេលវេលា សមស្របដើម្បីដោះស្រាយផងដែរ។ ក៏ប៉ុន្តែដោយមានកម្មវិធីនយោបាយច្បាស់លាស់ និងដោយមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពង្រឹងភាពជាដៃគូ រវាងស្ថាប័នរដ្ឋ សង្គមស៊ីវិល វិស័យឯកជន និងប្រជាពលរដ្ឋ យើងប្រាកដជានឹងអាចធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ក្នុងការលើកស្ទួយកម្រិតជីវភាព របស់ប្រជាជនយើង ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក** !

តាមរយៈវេទិកានេះ និងវឌ្ឍនភាពនៃការសំរេចបានដូចដែល ឯកឧត្តម **ឌី ច័ន្ទ្រផល** បានលើកឡើង ពិតជាបានឆ្លុះបញ្ចាំងឱ្យយើងទាំងអស់គ្នា ឃើញកាន់តែច្បាស់អំពីអត្ថប្រយោជន៍នៃការកែលម្អអភិបាលកិច្ច និងការកសាងហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យ រួមចំណែកដល់ការកាត់បន្ថយភាពអសកម្ម និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ជួយការពារដល់ការថែរក្សាសណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់ជីវភាព ប្រជាពលរដ្ឋតាមរយៈការលើកទឹកចិត្តអោយមានការចូលរួមរបស់សាធារណៈជន និងការទទួលខុសត្រូវរបស់អជ្ញាធរពាក់ព័ន្ធគ្រប់កំរិតក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន។ ក្នុងន័យនេះ ខ្ញុំសូមធ្វើការកត់សម្គាល់ និងវាយតម្លៃខ្ពស់ចំពោះពីជោគរបស់គម្រោង អភិបាលកិច្ចល្អមូលដ្ឋានដូចខាងក្រោម៖

១-ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ បានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់គុណភាពនៃការផ្តល់សេវារដ្ឋបាលដែលជាឧបករណ៍ដ៏មានសារៈសំខាន់ដើម្បីប្រែក្លាយរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យមានគុណភាព និងមានសមត្ថភាពខ្ពស់ជាងមុន ក្នុងការផ្តល់សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព គណនេយ្យភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការបានល្អប្រសើរ ។ ជាមួយគ្នានេះក៏បានធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមាន នូវផ្នត់គំនិត ឥរិយាបថ អាកប្បកិរិយា គុណតម្លៃរបស់មន្ត្រី បុគ្គលិក និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌអោយក្លាយខ្លួនទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព ដោយបំពេញការងាររបស់ខ្លួនប្រកបដោយឆន្ទៈមោះមុត មានភក្តីភាពចំពោះរដ្ឋ និងប្រជាពលរដ្ឋ ព្រមទាំងមាន សីលធម៌វិជ្ជាជីវៈខ្ពស់។ គំរូអនុវត្តល្អៗទាំងនេះពិតជានឹងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការពិចារណាឃើញភាពពង្រីកអោយបានទូទាំងប្រទេសនៅពេលអនាគត។

២-*ក្រុមប្រឹក្សាអាជ្ញាកណ្តាល* គឺជាស្ថាប័នឯករាជមួយនៅកម្ពុជា ទទួលបន្ទុកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ *ក្រុមប្រឹក្សាអាជ្ញាកណ្តាល* ទទួលបន្ទុកដោះស្រាយបណ្តឹងអំពីការរំលោភលើសិទ្ធិការងារ និងដោះស្រាយវិវាទនៅទីកន្លែងធ្វើការតាមរយៈការចូលរួមដោយផ្ទាល់របស់កម្មករ-និយោជិត និងនិយោជក។ ស្ថាប័ននេះដោះស្រាយវិវាទការងាររួមនៅកន្លែងការងារ ដែលអាចបង្កឲ្យមានកូដកម្ម ឬបាតុភាពផ្សេងៗធ្វើឲ្យបាត់បង់ប្រាក់ចំណូល ព្រមទាំងអាចឈានដល់អំពើហឹង្សាជាយថាហេតុ។ សេវាកម្មនៅ *ក្រុមប្រឹក្សាអាជ្ញាកណ្តាលកន្លងទៅ*បានរួមចំណែកធ្វើឲ្យប្រសើរឡើង នូវការអនុវត្តន៍ការងារជាក់ស្តែងជាពិសេស ការកលើកកម្ពស់ការគោរព ច្បាប់ស្តីពី ការងារ ក្នុងការកាត់បន្ថយ វិធានការរារាំងដំណើរការការងាររោងចក្រ(industrial action) និងក្នុងការជំរុញកិច្ចសហប្រតិបត្តិការ និងការចរចារតាមបែបស្ថាបនា ដោះស្រាយវិវាទការងារ។

៣-ការិយាល័យសម្របសម្រួលគម្រោង ដែលបច្ចុប្បន្នក្លាយជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអភិបាលកិច្ច នឹងបន្តអនុវត្តសមាសភាគសិក្សា របស់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន ដោយត្រូវដើរតួរជាបណ្ណាល័យ ស្ថាប័នសិក្សាស្រាវជ្រាវ ស្ថាប័នបណ្តុះបណ្តាល ដល់អជ្ញាធរគ្រប់កំរិតរដ្ឋបាល និង មន្ត្រីសង្គមស៊ីវិលអំពីគោលគំនិតនៃការងារអភិបាលកិច្ច។ មជ្ឈមណ្ឌលនេះក៏ជាវេទិកាអព្យាក្រិតសំរាប់ពង្រឹងភាព ជាដៃគូរវាង

ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋ សំដៅរួមចំណែកកែលម្អអភិបាលកិច្ច ការផ្តល់សេវា និងការអភិវឌ្ឍន៍ មូលដ្ឋានឱ្យកាន់តែប្រសើរឡើងក្នុងគោលដៅ រួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន ទូទាំងប្រទេស។

៤-***ស្ថាប័នមិនមែនរដ្ឋ*** (NSAC) មានគោលដៅជំរុញការចូលរួមរបស់ពលរដ្ឋនៅក្នុងវិស័យសាធារណៈ បង្កើនការទទួលបាននូវសេវាសាធារណៈ និងពង្រឹងសមត្ថភាពសង្គមស៊ីវិល និងស្ថាប័នមិនមែនរដ្ឋដទៃៗទៀត ដើម្បីជម្រុញមានគណនេយ្យភាពរបស់រដ្ឋ ។ ខ្ញុំក្នុងនាមប្រធាន គ.ជ.អ.ប នៅថ្ងៃទី១១ខែកក្កដាឆ្នាំ ២០១៤បានចុះហត្ថលេខា ដាក់អោយប្រើប្រាស់ផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងដោយមានការចូលរួមពីក្រសួងសុខាភិបាល ហើយក្រសួងអប់រំ យុវជន និងកីឡា គ.ជ.អ.ប ក៏បានរៀបចំ នូវផែនការអនុវត្ត៣ឆ្នាំ ២០១៤ -២០១៧ ដែលនៅតែត្រូវការអង្គការ សង្គមស៊ីវិលចូលរួម ជំរុញសិទ្ធទទួលបាននូវព័ត៍មានប្រជាពលរដ្ឋ ជួយក្នុងការកសាងសមត្ថភាពដល់អង្គការសហគមន៍មូលដ្ឋាន ជួយកសាងភាពជាដៃគូ ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្របសម្រួលដល់ដំណើរការពិនិត្យតាមដានរបស់ពលរដ្ឋ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ខ្ញុំសង្ឃឹមជឿជាក់ថា ផ្អែកតាមសមិទ្ធិផលនិងទស្សនវិស័យខាងលើនេះ ពិតជាទុនមួយយ៉ាងសំខាន់ក្នុងដំណើរការពង្រឹងសមត្ថភាពស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងជំរុញការអនុវត្តគណនេយ្យភាពសង្គម ដែលជាមូលដ្ឋាននៃការពង្រឹងលទ្ធិប្រជាធិបតេយ្យនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

តាមរយៈវេទិកានេះ ខ្ញុំសូមអំពាវនាវឱ្យមានការចូលរួមយ៉ាងសកម្មបន្ថែមទៀត ពីដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ជាមួយរាជរដ្ឋាភិបាល ដើម្បីបង្កើតបរិយាកាសសហប្រតិបត្តិការឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងការជំរុញកំណែទម្រង់ ពង្រឹងគុណភាពអភិបាលកិច្ច ដែលជាកត្តាដ៏ចាំបាច់បំផុតសម្រាប់ធានាចីរភាពនៃអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ជាថ្មីម្តងទៀតក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់ធនាគារពិភពលោក ដៃគូអភិវឌ្ឍន៍នានានិង អង្គការសង្គមស៊ីវិល ដែលបានចូលរួមជាមូលនិធិ ជាការស្ម័គ្រចិត្ត និងធនធានផ្សេងៗទៀត ដល់ដំណើរការអនុវត្តគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន រហូតទទួលបានសមិទ្ធិផលដូចពេលនេះ ។

ខ្ញុំសូមប្រសិទ្ធពរ បវរមហាប្រសើរ ជូនចំពោះឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាមន្ត្រីរាជការ តំណាងអង្គការសង្គមស៊ីវិល និងអង្គវេទិកាទាំងមូល សូមមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

**ខ្ញុំសូមប្រកាសបិទ វេទិកា គណនេយ្យភាពសង្គមចាប់ពីពេលនេះតទៅ។**

***សូមអរគុណ !***